អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## វិភាគទានចំនួន ៦ លានក្រូន័ររបស់ប្រទេសន័រវេ ត្រូវបានផ្ទេរទៅកាន់ភាគីជាតិនៃអ.វ.ត.ក

រដ្ឋាភិបាលនៃប្រទេសន័រវេ បានអនុម័តយល់ព្រមថាវិភាគទានហិរញ្ញវត្ថុរបស់ខ្លួនចំនួនទឹកប្រាក់ ៦ លានក្រូន័រ (ប្រមាណ ១ លានដុល្លារអាម៉េរិក) ដែលផ្តល់ជូននាពេលថ្មីៗកន្លងទៅនេះ អាចបង្វែរពីភាគីអន្តរជាតិទៅភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) វិញ ដើម្បីចំណាយលើប្រាក់បៀវត្សរ៍របស់មន្ត្រីបុគ្គលិកភាគីជាតិ។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក បានថ្លែងថា៖ “ក្នុងនាម អ.វ.ត.ក ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅ ចំពោះអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលន័រវេ ចំពោះការពិចារណាផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុនេះបានទាន់ពេលវេលា។ ជាមួយថវិកានេះ ភាគីជាតិនៃ អ.វ.ត.ក មានលទ្ធភាពក្នុងការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រី បុគ្គលិករបស់ខ្លួន ចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ ២០១៤។ ជាមួយគ្នានេះផងដែរ ខ្ញុំក៏សូមអំពាវនាវជាឱឡារិកដល់សហគមន៍ម្ចាស់ជំនួយទាំងអស់បន្តផ្តល់វិភាគទានហិរញ្ញវត្ថុចាំបាច់បន្ថែមទៀត ដើម្បីបំពេញថវិកាដែលនៅខ្វះ ក្នុងគម្រោងថវិកាឆ្នាំ ២០១៤ របស់ភាគីជាតិនៃអ.វ.ត.ក”។

រហូតមកទល់ពេលនេះ ប្រទេសន័រវេ បានផ្តល់វិភាគទានហិរញ្ញវត្ថុមកកាន់ អ.វ.ត.ក សរុបចំនួនជាង ៧ លានដុល្លារអាម៉េរិក និងបានគាំទ្រចំពោះសាលាក្តីនេះចាប់តាំងពីការបង្កើតដំបូងមកម្ល៉េះ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh